**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

**សំណុំរឿងលេខ** : ០០៤/២/០៧-០៩-២០០៩-អវតក/កសចស/(អបជ៦០)
**ដាក់ទៅ** : អង្គបុរេជំនុំជម្រះ
**ថ្ងៃដាក់** : ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២០
**ភាគីអ្នកដាក់** : សហព្រះរាជអាជ្ញាអន្តរជាតិ
**ភាសាដើម** : អង់គ្លេស

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 04-Feb-2020, 14:10
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយ អបជ:

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំឲ្យចាត់រាល់វិធានការរដ្ឋបាលដែលតម្រូវទាំងអស់ ដើម្បីបញ្ជូនសំណុំរឿង ០០៤/០២ (អោ អាន) ទៅអង្គជំនុំជម្រះសាលាដំបូង**

---

**អ្នកដាក់ឯកសារ:**
លោកស្រី Brenda J. Hollis
**សហព្រះរាជអាជ្ញាអន្តរជាតិ**

**ចម្លងជូន:**
លោកស្រី ជា លាង
**សហព្រះរាជអាជ្ញាជាតិ**

**អ្នកទទួលឯកសារ:**
**អង្គបុរេជំនុំជម្រះ**
ចៅក្រម ប្រាក់ គឹមសាន, ប្រធាន
ចៅក្រម Olivier BEAUVALLET
ចៅក្រម ន័យ ថុល
ចៅក្រម Kang Jin BAIK
ចៅក្រម ហួត វុទ្ធី

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ក្នុងសំណុំរឿង០០៤/២**

**សហមេធាវី អោ អាន**
លោក មុំ លុដ្ឋ
លោក Richard ROGERS
លោក Göran SLUITER

# I. សេចក្តីផ្តើម

1. សហព្រះរាជអាជ្ញាអន្តរជាតិ ("ស.ព.អ") ស្នើសុំដោយឲ្យអង្គបុរេជំនុំជម្រះ ("អ.ប.ជ") ចាត់វាល់វិធានការរដ្ឋបាលចាំបាច់ទាំងអស់ ដើម្បីបង្គាប់ឲ្យផ្នែកគ្រប់គ្រងតុលាការ ("CMS") បញ្ជូន (អនុញ្ញាតឲ្យចូលពិនិត្យមើលឯកសារតាមអេឡិចត្រូនិក) ដីការបញ្ជូនរឿងទៅជំនុំជម្រះ[1] ប្រសិនបើតម្រូវឲ្យមានវិធានការរដ្ឋបាលបន្ថែមទៀតទាក់ទងនឹងឯកសារសាធារណៈនេះ និងសំណុំរឿងសេសសល់ ក្នុងរឿងក្តី ០០៤/២ ទៅកាន់អង្គជំនុំជម្រះសាលាដំបូង ("អ.ជ.ស.ដ") ដែលរួមបញ្ចូលទាំងការដាក់ទម្រង់បែបបទរដ្ឋបាលសមស្រប ប្រសិនបើត្រូវបានតម្រូវ។

2. ស.ព.អ ធ្វើសំណើនេះដើម្បីដាក់ឲ្យដំណើរការ "គោលជំហរស្វ័យប្រវត្តិជាមូលដ្ឋាន និងជាកត្តាកំណត់"[2] ដែល អ.ប.ជ បានសម្រេចជាឯកច្ឆ័ន្ទថា "ជាមុខងារសំខាន់នៃក្របខណ្ឌគតិយុត្តិ អ.វ.ត.ក"[3] ដែលថា រឿងក្តីនេះត្រូវបន្តទៅជនុំជម្រះ ដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង អ.វ.ត.ក[4] ច្បាប់ អ.វ.ត.ក[5] និងវិធានផ្ទៃក្នុង ("វិធាន")[6]។ គោលជំហរជាស្វ័យប្រវត្តិដែលថា រឿងក្តីនេះត្រូវបន្តទៅជំនុំជម្រះ ត្រូវតែអនុវត្ត ដោយហេតុថា អ.ប.ជ ខកខានមិនអាចរកសំឡេងគាំទ្រយ៉ាងហោចណាស់ពីចៅក្រមបួនរូបក្នុងចំណោមចៅក្រមទាំងប្រាំរូប ដើម្បីបដិសេធដីការបញ្ជូនរឿងទៅជំនុំជម្រះ។ សំណើរនេះក៏ត្រូវបានធ្វើឡើងដើម្បីធានាថា អោ អាន ត្រូវបានជំនុំជម្រះយ៉ាងឆាប់រហ័ស ដូចដែលបានតម្រូវដោយមាត្រា ៣៣ថ្មី នៃច្បាប់ អ.វ.ត.ក។

---

[1] ឯកសារ **D360** ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ("ដីកាបញ្ជូនរឿងទៅជំនុំជម្រះ")។

[2] សំណុំរឿង០០៤/២ ឯកសារ **D359/24** & **D360/33**, សេចក្តីពិចារណារបស់លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ កថាខណ្ឌ ១១២។

[3] ឯកសារ **D359/24** & **D360/33** សេចក្តីពិចារណា កថាខណ្ឌ ១០៦។

[4] កិច្ចព្រមព្រៀងរវៀងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ ("កិច្ចព្រមព្រៀង អ.វ.ត.ក") មាត្រា ៥(៤), ៧(៤)។

[5] ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ដូចដែលបានវិសោធនកម្មនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ (នស/រកម/១០០៤/២០០៦) ("ច្បាប់ អ.វ.ត.ក") មាត្រា ២៣ថ្មី។

[6] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង (វិសោធនកម្មទី៩) ដូចដែលបានកែប្រែនៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ ("វិធានផ្ទៃក្នុង" ឬ "វិធាន") វិធាន ៧៧(១៣)(ខ), ៧៩(១)។

3. ស.ព.អ យល់ឃើញថា អ.ប.ជ ត្រូវចាត់វាល់វិធានការរដ្ឋបាលចាំបាច់ទាំងអស់ ដើម្បីធានានូវការបញ្ជូនដ៏ឆាប់រហ័សនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងសំណុំរឿង ទៅកាន់ អ.ជ.ស.ដ ដើម្បីតម្កល់សច្ចភាព និងតម្លាភាពផ្លូវច្បាប់ ដែលត្រូវបានកំណត់ដោយគោលជំហរស្វ័យប្រវត្តិ និងដែលត្រូវបានតម្រូវដោយវិធាន ២១(១)។

4. សន្និដ្ឋានថា ផលប៉ះពាល់នៃការខកខានជាបន្តទៀតក្នុងការមិនបានអនុញ្ញាតឱ្យ អ.ជ.ស.ដ ចូលពិនិត្យមើលសំណុំរឿងនេះ នឹងផ្ទុយទៅនឹងលក្ខខណ្ឌតម្រូវនានានៃគោលជំហរស្វ័យប្រវត្តិ បដិសេធសិទ្ធិរបស់ជនរងគ្រោះ ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការទទួលបានយុត្តិធម៌ និងធ្វើឱ្យខូចខាតដល់សេចក្ដីថ្លៃថ្នូរនៃដំណើរការរបស់ អ.វ.ត.ក និងបង្អាក់សណ្ដាប់ធ្នាប់កិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះនៅក្នុងរឿងក្ដីនេះ។

## II. ប្រវត្តិនីតិវិធី

5. នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ អ.ប.ជ បានជូនដំណឹងអំពីសេចក្ដីពិចារណារបស់ខ្លួនក្នុងសំណុំរឿងនេះ[7]។ អ.ប.ជ ខកខានមិនបានឈានទៅដល់សេចក្ដីសម្រេចមួយដែលមានសំឡេងលើសលុប (សំឡេងគាំទ្រពីចៅក្រមយ៉ាងហោចណាស់បួនរូប ក្នុងចំណោមចៅក្រមប្រាំរូប) ដែលត្រូវការដើម្បីបដិសេធដីកាសម្រេចលើកលែងចោទប្រកាន់[8] ឬ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

6. ជាវិបាក កថាខណ្ឌ ៦៨៧ នៃសេចក្ដីពិចារណានេះបានបង្គាប់ ក្នុងផ្នែកដែលពាក់ព័ន្ធ ថា "ក្រឡាបញ្ជីនៃអង្គបុរេជំនុំជម្រះនឹងបញ្ជូនដីកាសម្រេចនេះ រួមជាមួយដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ និងសំណុំរឿងដែលនៅសេសសល់ទៅអង្គជំនុំជម្រះសាលាដំបូង"។

7. បញ្ជីឈ្មោះចម្លងជូននៃអ្នកដែលត្រូវបានជូនដំណឹងអំពីសេចក្ដីពិចារណានេះរួមបញ្ចូល ក្រឡាបញ្ជី អ.ជ.ស.ដ និងចៅក្រម អ.ជ.ស.ដ ចំនួនពីររូប[9]។ ទោះជាយ៉ាងណា អ.ជ.ស.ដ បានជូនដំណឹង

---

[7] អ៊ីម៉ែលពីមន្ត្រីទទួលបន្ទុកសំណុំរឿង ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ("អ៊ីម៉ែល ជូនដំណឹងរបស់ អ.ប.ជ") ម៉ោង ៤:៥៣ ល្ងាច។

[8] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ អោ អាន ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨។

[9] សូមមើល អ៊ីម៉ែល ជូនដំណឹងរបស់ អ.ប.ជ។ បញ្ជីចម្លងជូនរួមមានឈ្មោះចៅក្រម អ.ជ.ស.ដ ពីររូប គឺចៅក្រម Claudia Fenz និងចៅក្រម Martin Karopkin ក៏ដូចជាក្រឡាបញ្ជី អ.ជ.ស.ដ និងមន្ត្រីច្បាប់ លឹម ស៊ុយហុង។ *ផ្ទុយពី* អ៊ីម៉ែលមានចំណងជើងថា "ព័ត៌មាន" ដែលបញ្ជូនដោយ លឹម ស៊ុយហុង តាងនាមឱ្យ អ.ជ.ស.ដ នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០២០ វេលាម៉ោង ១.៤៨ រសៀល ដែលបានថ្លែងថា៖ "សេចក្ដីពិចារណាទាំងអស់នេះមិនទាន់បានជូនដំណឹងមកកាន់អង្គជំនុំជម្រះនៅឡើយទេមកទល់ពេលនេះ"។

ចៅក្រម អ.ប.ជ ការិយាល័យរដ្ឋបាល អោ អាន និងសហព្រះរាជអាជ្ញាថា ត្រឹមថ្ងៃទី២១ ខែមករា ឆ្នាំ២០២០ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងសំណុំរឿងនេះ មិនទាន់ត្រូវបានបញ្ជូនទៅ អ.ជ.ស.ដ នៅឡើយទេ[10]។

8. មកទល់ពេលនេះ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងសំណុំរឿងនេះ នៅតែមិនទាន់ត្រូវបានបញ្ជូនទៅ អ.ជ.ស.ដ នៅឡើយ។

## III. ច្បាប់ជាធរមាន

9. មាត្រា ៥(៤) នៃកិច្ចព្រមព្រៀង អ.វ.ត.ក ចែងថា៖

> សហចៅក្រមស៊ើបអង្កេតត្រូវសហការគ្នា ដើម្បីឈានទៅដល់ការឯកភាពគ្នាមួយក្នុងការស៊ើបអង្កេត។ នៅក្នុងករណីដែលចៅក្រមស៊ើបអង្កេតមិនអាចឯកភាពគ្នាថាត្រូវបន្តការស៊ើបអង្កេតណាមួយ **ការស៊ើបអង្កេតនោះ ត្រូវដំណើរការទៅមុខទៀត លើកលែងតែចៅក្រមទាំងនេះ ឬចៅក្រមណាម្នាក់ក្នុងចំណោមចៅក្រមទាំងនេះ ធ្វើការស្នើសុំនៅក្នុងរយៈ ពេលសាមសិបថ្ងៃ ឱ្យដោះស្រាយការខ្វែងគំនិតគ្នានេះ** តាមមាត្រា ៧[11]។

10. មាត្រា ៧(៤) នៃកិច្ចព្រមព្រៀង អ.វ.ត.ក ចែងថា៖

> **ការសម្រេចសេចក្ដីរបស់អង្គបុរេជំនុំជម្រះ ដែលមិនអាចប្ដឹងឧទ្ធរណ៍បាន ត្រូវមានសំឡេងឆ្នោតគាំទ្រដោយចៅក្រមយ៉ាងតិចបួនរូប។** ការសម្រេចសេចក្ដីនេះ ត្រូវជូនដល់ប្រធានរដ្ឋបាលដែលនឹងផ្សព្វផ្សាយ ហើយចែកជូនដល់សហចៅក្រមស៊ើបអង្កេត ឬសហព្រះរាជអាជ្ញា។ **សហចៅក្រមស៊ើបអង្កេត ឬសហព្រះរាជអាជ្ញា**

---

[10] អ៊ីម៉ែលមានចំណងជើងថា "ព័ត៌មាន" ដែលបញ្ជូនដោយ លឹម ស៊ុយហុង តាងនាមឱ្យ អ.ជ.ស.ដ នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០២០ វេលាម៉ោង ១.៤៨ រសៀល ដែលបានថ្លែងថា៖ "អង្គជំនុំជម្រះបានសុំឱ្យខ្ញុំជូនដំណឹងអ្នកដូចខាងក្រោមនេះ៖ អង្គជំនុំជម្រះបានដឹងអំពីសេចក្ដីពិចារណាដែលមាជាសាធារណៈស្ដីពីបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ដែលបានចេញដោយអង្គបុរេជំនុំជម្រះនៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ និងឯកសារដែលអ្នកបានបញ្ជូនមកកាន់អង្គជំនុំជម្រះសាលាដំបូង។ ទោះជាយ៉ាងណា សេចក្ដីពិចារណាទាំងអស់នេះមិនទាន់បានជូនដំណឹងមកកាន់អង្គជំនុំជម្រះនៅឡើយទេមកទល់ពេលនេះ ហើយដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងសំណុំរឿងក៏មិនត្រូវបានបញ្ជូនមកនៅឡើយដែរ"។ អ៊ីម៉ែលនេះត្រូវបានបញ្ជូនទៅកាន់ចៅក្រមសហព្រះរាជអាជ្ញា ក្រុមមេធាវីការពារក្ដី អោ អាន អង្គបុរេជំនុំជម្រះ និង ប្រធាន និងអនុប្រធានការិយាល័យរដ្ឋបាល។ (អ៊ីម៉ែលរបស់ក្រឡាបញ្ជី អ.ជ.ស.ដ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២០)។

[11] គូសបញ្ជាក់បន្ថែម។

**នឹងត្រូវដំណើរការភ្លាមៗ ស្របទៅតាមការសម្រេចរបស់អង្គបុរេជំនុំជម្រះ។ ប្រសិនបើគ្មានមតិភាគច្រើន ដែលត្រូវការសម្រាប់ធ្វើការសម្រេចសេចក្តីទេ ការស៊ើបអង្កេត ឬការចោទប្រកាន់នឹងត្រូវបន្តដំណើរការទៅមុខទៀត**[12]។

11. មាត្រា ២៣ថ្មី នៃច្បាប់ អ.វ.ត.ក ចែងថា៖

**សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះដែលពុំបើកផ្លូវឱ្យមានបណ្តឹងឧទ្ធរណ៍ តម្រូវឱ្យមានសំឡេងវិជ្ជមានពីចៅក្រមបួនរូបយ៉ាងតិច។** សេចក្តីសំរេចនេះត្រូវជូនដំណឹងដល់ប្រធានការិយាល័យរដ្ឋបាលដែលត្រូវផ្សព្វផ្សាយសេចក្តីសម្រេចនេះ ហើយជូនដំណឹងដល់សហចៅក្រមស៊ើបអង្កេត។ **សហចៅក្រមស៊ើបអង្កេតត្រូវចាត់ការបន្តជាបន្ទាន់ ដោយអនុវត្តតាមសេចក្តីម្រេចរបស់អង្គបុរេជំនុំជម្រះនេះ។ ប្រសិនបើពុំមានមតិភាគច្រើនដូចដែលតម្រូវឱ្យមានចំពោះសេចក្តីសម្រេច ការស៊ើបអង្កេតត្រូវធ្វើបន្តទៀត**[13]។

12. មាត្រា ៣៣ថ្មី នៃច្បាប់ អ.វ.ត.ក ចែងថា៖

អង្គជំនុំជម្រះវិសាមញ្ញរបស់សាលា ដំបូងត្រូវអនុវត្តយុត្តាធិការរបស់ខ្លួនសមស្របតាម**បទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវនឹងដំណើរការសមស្របនៃច្បាប់ ដូចដែលបានចែងក្នុងមាត្រា១៤ និង១៥ នៃអនុសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ**[14]។

13. វិធាន ២១(១) ចែងថា៖

ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាល ទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទជនជាប់ចោទ និង ជនរងគ្រោះ ដើម្បី**ធានាអំពីសច្ចភាពផ្លូវច្បាប់ និង កិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព** ដោយគិតដល់លក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញ

[12] គូសបញ្ជាក់បន្ថែម។

[13] គូសបញ្ជាក់បន្ថែម។

[14] គូសបញ្ជាក់បន្ថែម។

ក្នុងតុលាការកម្ពុជា ដូចមានចែងក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងកិច្ចព្រមព្រៀង [...][15]។

14. វិធាន ៦៩(៣) ចែងថា៖

ការដាក់ពាក្យប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ មិនរារាំងអង្គជំនុំជម្រះសាលាដំបូង និងសហ**មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការមើលសំណុំរឿង ក្នុងគោលបំណងត្រៀមរៀបចំជាមុនសម្រាប់ការជំនុំជម្រះទេ**[16]។

15. វិធាន ៧៧(១៣) ចែងថា៖

សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ តម្រូវឲ្យមានសម្លេងគាំទ្រជាវិជ្ជមានពីចៅក្រម៤(បួន)រូបយ៉ាងតិច ។ សេចក្តីសម្រេចនេះត្រូវបិទផ្លូវតវ៉ា។ ប្រសិនបើសម្លេងភាគច្រើនដែលតម្រូវមិនអាចរកបានទេ **សេចក្តីសម្រេចដែលមិនមានសម្លេងគាំទ្រ**របស់អង្គបុរេជំនុំជម្រះ**ត្រូវ**អនុវត្តដូចខាងក្រោម៖ [...]

ខ-ក្នុងករណីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេត **ប្រសិនបើមិនអាចរកសម្លេងភាគច្រើនដែលតម្រូវបាននោះទេ អង្គបុរេជំនុំជម្រះ ត្រូវសម្រេចបញ្ជូនទៅអង្គជំនុំជម្រះសាលាដំបូង ដោយឈរលើមូលដ្ឋានដីកាដំណោះស្រាយ**របស់សហចៅក្រមស៊ើបអង្កេត[17]។

16. វិធាន ៧៩(១) ចែងថា៖

អង្គជំនុំជម្រះសាលាដំបូងទទួលបណ្តឹង ដោយដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេត ឬ តាមសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ។

17. កថាខណ្ឌ ៤១ នៃសេចក្តីពិចារណាលើកឡើងថា៖

---

[15] គូសបញ្ជាក់បន្ថែម។

[16] គូសបញ្ជាក់បន្ថែម។

[17] គូសបញ្ជាក់បន្ថែម។

ដោយមិគិតពីឈ្មោះរបស់វា ជាសភាស៊ើបសួរទីពីរ សភាចោទប្រកាន់ ឬអង្គបុរេជំនុំជម្រះ **អង្គជំនុំជម្រះបច្ចុប្បន្ននេះជាយុត្តាធិការចុងក្រោយបង្អស់លើដំណាក់កាលបុរេជំនុំជម្រះនៅ អ.វ.ត.ក** [...][18]។

18. កថាខណ្ឌ ៦៨ នៃសេចក្ដីពិចារណាលើកឡើងថា៖

នៅដំណាក់កាលនេះ អង្គបុរេជំនុំជម្រះរម្លឹកអំពីកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនចំពោះ **សច្ចភាពផ្លូវច្បាប់** និងកិច្ចដំណើរការនីតិវិធីប្រកបដោយ**តម្លាភាព [...]**[19]។

19. កថាខណ្ឌ ១០៩ នៃសេចក្ដីពិចារណាទទួលស្គាល់គោលការណ៍ចំបងនេះថា៖

កិច្ចដំណើរការនីតិវិធី អ.វ.ត.ក ចាំបាច់ត្រូវគោរពតាមលក្ខណ្ឌតម្រូវ ប្រសិទ្ធិភាព នីត្យានុកូលភាព ភាពយុត្តិធម៌ តាមក្របខណ្ឌគតិយុត្តិ អ.វ.ត.ក។ ក្នុងករណីនេះ លក្ខខណ្ឌតម្រូវនៃយុត្តិធម៌ព្រហ្មទណ្ឌប្រកបដោយប្រសិទ្ធិភាព មានតម្លៃសម្រាប់ការយកចិត្តទុកដាក់ជាពិសេសរបស់អង្គជំនុំជម្រះនេះ។

20. កថាខណ្ឌ ១១២ នៃសេចក្ដីពិចារណាសង្កត់ធ្ងន់ថា៖

**គោលការណ៍ដែលជាមូលដ្ឋាន និងជាកត្តាកំណត់ចំពោះគោលជំហរជាក់ស្ដែង មិនអាច**ត្រូវបានទាត់ចោល ឬដកហូតឥទ្ធិពល និងទម្ងន់ពេញទាំងស្រុងរបស់វា ដោយការរៀបចំការបកស្រាយជាបណ្ដាញ តាមរយៈការកេងចំណេញពីភាពមិនច្បាស់លាស់ដែលអាចមាននៅក្នុងច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក និងវិធានផ្ទៃក្នុង ដើម្បីធ្វើឱ្យគោលការណ៍ស្នូលនេះក្លាយទៅជាគ្មានន័យនោះទេ។ ការសម្រេចផ្សេងពីនេះ នឹងនាំទៅដល់លទ្ធផលផ្លូវច្បាប់ ដែលមិនសមហេតុផលទាល់តែសោះ ដោយរំលោភបំពានទាំងទៅលើច្បាប់អន្តរជាតិ និងច្បាប់កម្ពុជា[20]។

21. កថាខណ្ឌ ១២២ នៃសេចក្ដីពិចារណាក៏លើកឡើងថា៖

**ភារកិច្ចតាមផ្លូវតុលាការក្នុងការប្រកាស ដោយផ្អែកទៅលើច្បាប់ សេចក្ដីសម្រេចលើបញ្ហាដែលមានវិវាទ** *(jurisdictio)* **គឺជាចំណុចសំខាន់បំផុតនៃការទទួលខុសត្រូវ**

---

[18] គូសបញ្ជាក់បន្ថែម។

[19] គូសបញ្ជាក់បន្ថែម។

[20] គូសបញ្ជាក់បន្ថែម។

**និងមុខងារដឹកនាំខ្ពស់បំផុតរបស់ចៅក្រម។** ហេតុដូច្នេះ ការប្រកាសសម្រេចវិនិច្ឆ័យ និងការដោះស្រាយបញ្ហាដែលជាជម្លោះ ត្រូវមានឥទ្ធិពល និងជាកាតព្វកិច្ចផ្លូវច្បាប់ *(imperium)* ដែលខុសពីសារណារបស់ភាគី។ ចៅក្រមអាចមានកំហុសលើសេចក្ដីសម្រេច ដែលអាចត្រូវបានកែតម្រូវនៅដំណាក់កាលបណ្ដឹងឧទ្ធរណ៍។ ប៉ុន្តែចៅក្រមមិនអាចគេចចេញពីការវិនិច្ឆ័យលើបញ្ហាដែលនៅចំពោះមុខខ្លួន ឬគេចចេញពីការឈានទៅសន្និដ្ឋាន ដែលសម្រេចដោយប្រសិទ្ធភាពទៅលើបញ្ហានេះនោះទេ[21]។

22. កថាខណ្ឌ ៦៨៧ នៃសេចក្ដីពិចារណាលើកឡើងថា៖

ដោយផ្អែកទៅលើពាក្យពេចន៍ច្បាស់លាស់នៃវិធាន ៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុង **ការដែលអង្គបុរេជំនុំជម្រះមិនអាចឈានទៅដល់សេចក្ដីសម្រេចដោយសំឡេងភាគច្រើនលើសលប់ ដោយចៅក្រមយ៉ាងតិចបួនរូបនោះ មិនបានរារាំងដល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ រួមជាមួយនឹងសំណុំរឿង មិនឲ្យបញ្ជូនទៅអង្គជំនុំជម្រះសាលាដំបូង ដើម្បីឲ្យអង្គជំនុំជម្រះសាលាដំបូងអាចចាប់ផ្ដើមកិច្ចដំណើរការនីតិវិធីជំនុំជម្រះប្រឆាំងនឹង អោ អាន។** ស្របជាមួយបទប្បញ្ញត្តិនេះ ក្រឡាបញ្ជីនៃអង្គជំនុំជម្រះ នឹងបញ្ជូនដីកាសម្រេចនេះ រួមជាមួយដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ និងសំណុំរឿងដែលនៅសេសសល់ ទៅអង្គជំនុំជម្រះសាលាដំបូង[22]។

## IV. **សេចក្ដីសន្និដ្ឋាន**

23. អនុលោមតាមវិធាន ៧៧(១៣)(ខ) និង ៧៩(១) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូងត្រូវបានប្ដឹងដោយស្វ័យប្រវត្តិអំពីសំណុំរឿងនេះនៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ដោយសារបរាជ័យរបស់ អ.ប.ជ មិនអាចរកបាននូវសំឡេងភាគច្រើនលើសលុប ដើម្បីបដិសេធដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ អាស្រ័យហេតុនេះ ដោយសារការខកខានមិនអាចរកសេចក្ដីសម្រេចដែលមានសំឡេងគាំទ្រលើសលុបបានដូច្នេះ ទើបធ្វើឲ្យ "គោលជំហរស្វ័យប្រវត្តិជាមូលដ្ឋាន និងជាកត្តាកំណត់នេះ" ដាក់កាតព្វកិច្ចឲ្យ អ.ប.ជ ចាត់វិធានការរដ្ឋបាលជាបន្ទាន់ ដើម្បីបញ្ជូនដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងសំណុំរឿងនេះទៅ អ.ជ.ស.ដ ដើម្បីបើកសវនាការជំនុំជម្រះលើបុគ្គល អោ អាន ឲ្យបានឆាប់ស្របតាម មាត្រា ៣៣ថ្មី នៃច្បាប់ អ.វ.ត.ក។ វិបាក*រដ្ឋបាល* ដែល អ.ជ.ស.ដ ត្រូវបានប្ដឹងអំពី

---

[21] គូសបញ្ជាក់បន្ថែម។

[22] គូសបញ្ជាក់បន្ថែម។

រឿងនេះគឺថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងសំណុំរឿងដែលនៅសេសសល់ ត្រូវតែបញ្ជូនទៅ អ.ជ.ស.ដ។ ជាងប្រាំមួយសប្តាហ៍បានកន្លងផុតទៅតាំងពីសេចក្តីពិចារណាបានចេញ ប៉ុន្តែ អ.ជ.ស.ដ នៅតែមិនទាន់បានទទួលសិទ្ធិចូលពិនិត្យដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬសំណុំរឿង នៅឡើយ។

24. ដើម្បីបញ្ចៀសការពន្យារពេលរដ្ឋបាលបន្ថែម ស.ច.ព សូមស្នើថា វិធានការរដ្ឋបាលចាំបាច់ទាំងអស់ត្រូវបានធ្វើឡើងដើម្បីធានាដល់ការបញ្ជូនយ៉ាងមានប្រសិទ្ធិភាពនូវដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងសំណុំរឿង ទៅ អ.ជ.ស.ដ យ៉ាងឆាប់រហ័សតាមដែលអាចធ្វើបាន។ ស.ព.អ យល់ថា ទោះបីជាមានពាក្យពេចន៍មិនច្បាស់លាស់របស់សេចក្តីណែនាំរបស់ពួកគេក៏ដោយ ក៏អង្គភាពគ្រប់គ្រងតុលាការកំពុងតែរង់ចាំឱ្យ អ.ប.ជ ចាត់វិធានការរដ្ឋបាលដើម្បីឱ្យការបញ្ជូនអាចដំណើរការបាន។ គេជឿថា វិធានការរដ្ឋបាលនេះ គឺគ្រាន់តែត្រូវការទម្រង់រដ្ឋបាលមួយ ដើម្បីផ្តល់ទៅផ្នែកគ្រប់គ្រងតុលាការឱ្យប្រកាន់ជំហរតាមសេចក្តីណែនាំដូចមានចែងក្នុងកថាខណ្ឌ ៦៨៧ នៃសេចក្តីពិចារណាសម្រាប់ក្រឡាបញ្ជី អ.ប.ជ អនុវត្តឱ្យមានប្រសិទ្ធិភាពនៃការបញ្ជូននេះ។ ស.ព.អ ក៏យល់ផងដែរថា ទោះបីជាមានពាក្យពេចន៍មិនច្បាស់លាស់ក៏ដោយ សេចក្តីណែនាំដែលមានក្នុងកថាខណ្ឌ ៦៨៧ នៃសេចក្តីពិចារណារបស់ អ.ប.ជ ដែលថា "ក្រឡាបញ្ជីនៃអង្គបុរេជំនុំជម្រះនឹងបញ្ជូនដីកាសម្រេចនេះ [ដីកាបញ្ជូនរឿងទៅជំនុំជម្រះ] និងសំណុំរឿង ដែលនៅ សេសសល់ ទៅអង្គជំនុំជម្រះសាលាដំបូង" នោះ គឺជាសិទ្ធិអំណាចគ្រប់គ្រាន់សម្រាប់ក្រឡាបញ្ជី អ.ប.ជ (ជាតិ និងអន្តរជាតិ) និង/ឬ អង្គភាពគ្រប់គ្រងតុលាការ ត្រូវចាត់វិធានការចាំបាច់ទាំង នេះ។

25. ស.ព.អ សន្និដ្ឋានថា តាំងតែពីពេលដែលអង្គជំនុំជម្រះនេះបានចេញសេចក្តីពិចារណារបស់ខ្លួន វិធានការដែលនៅសេសសល់តែមួយគត់សម្រាប់ អ.ប.ជ ត្រូវធ្វើដើម្បីផ្តល់លទ្ធភាពឱ្យ អ.ជ.ស.ដ ដំណើរការទៅមុខចំពោះសំណុំរឿង ០០៤/២ គឺវិធានការរដ្ឋបាល។ វិធានការនេះ គឺជារឿងចាំបាច់ដើម្បីឱ្យការបញ្ជូនទៅ អ.ជ.ស.ដ នៃសំណុំរឿងដែលនៅសេសសល់ និងដីកាបញ្ជូនរឿងទៅជំនុំជម្រះមានប្រសិទ្ធិភាព ប្រសិនបើវិធានការរដ្ឋបាលបន្ថែមទៀតត្រូវបានតម្រូវ។ ស.ព.អ សន្និដ្ឋានថា វិធានការដូច្នេះត្រូវតែអនុវត្តជាបន្ទាន់ដើម្បី "គោលជំហរស្វ័យប្រវត្តិជាមូលដ្ឋាន និងជាកត្តាកំណត់" មានប្រសិទ្ធិភាពទៅបាន ដូចបានកំណត់ដោយកិច្ចព្រមព្រៀង អ.វ.ត.ក ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងវិធានផ្ទៃក្នុង។

26. ស.ព.អ សន្និដ្ឋានបន្ថែមថា ជាសំខាន់មិនត្រូវឱ្យមានការពន្យារពេល ឧបសគ្គ ឬការរារាំងបន្ថែមដែលធ្វើឱ្យមានការពន្យារពេលដល់ដំណើរការនៃរឿងក្តីនេះនៅចំពោះមុខ អ.ជ.ស.ដ ទៀតឡើយ។

បើមិនដូច្នោះទេ តុលាការនឹងមានហានិភ័យក្នុងការកំណត់អាទិភាពអំពីសារធាតុ និងបច្ចេកទេសនៅលើគោលការណ៍ស្នូល។ ដោយសារអង្គជំនុំជម្រះនេះ បានសង្កត់ធ្ងន់នៅក្នុងសេចក្តីពិចារណារបស់ខ្លួន ថា "គោលជំហរស្វ័យប្រវត្តិជាមូលដ្ឋាន និងជាកត្តាកំណត់ មិនអាចត្រូវបានទាត់ចោល ឬដកហូតឥទ្ធិពល និងទម្ងន់ពេញទាំងស្រុងរបស់វា" ដោយសារ "ការរៀបចំការបកស្រាយជាបណ្តាញ" ដើម្បី "ធ្វើឱ្យគោលការណ៍ស្នូលនេះនៃកិច្ចព្រមព្រៀង អ.វ.ត.ក នេះ ក្លាយទៅជាឥតន័យនោះទេ"[23] ។ បន្ទាប់មក អង្គជំនុំជម្រះនេះ បានធ្វើការសន្និដ្ឋានតាមរយៈការសម្រេចថា ការធ្វើដូច្នេះនឹង "នាំទៅដល់លទ្ធផលផ្លូវច្បាប់ដែលមិនសមហេតុផលទាល់តែសោះ ដោយរំលោភទាំងទៅលើច្បាប់អន្តរជាតិ និងច្បាប់កម្ពុជា"[24]។

27. ការពន្យារពេលបន្ថែមក្នុងការផ្តល់សិទ្ធិចូលពិនិត្យមើលសំណុំរឿងដល់ អ.ជ.ស.ដ ធ្វើឱ្យខូចដល់សច្ចភាព និងតម្លាភាពផ្លូវច្បាប់ដែលបានផ្តល់ដោយសេចក្តីសម្រេចស្វ័យប្រវត្តិ និងដែលបានតម្រូវដោយវិធាន ២១(១) នៃវិធានផ្ទៃក្នុង។ ការពន្យារពេលដែលបានជួបប្រទះនេះ ធ្វើឱ្យមានភាពមិនច្បាស់លាស់ដល់ជនជាប់ចោទ គូភាគី ប្រជាពលរដ្ឋកម្ពុជា និងសហគមន៍អន្តរជាតិ ថាតើជនជនជាប់ចោទរូបនេះ នឹងត្រូវចូលខ្លួនមកកាន់សវនាការជំនុំជម្រះដែរឬទេ ឬមួយថាតើត្រូវទុកឱ្យបទចោទធ្ងន់ធ្ងរដែលមានវិវាទទាំងនោះ ស្ថិតក្នុងស្ថានភាពមិនប្រាកដប្រជាខាងផ្លូវច្បាប់ជារៀងរហូត។ ភាពមិនប្រាកដប្រជាដូច្នេះ គឺផ្ទុយទៅនឹង "គោលការណ៍បដិសេធ" ដែលបានទទួលស្គាល់ថា "កិច្ចដំណើរការនីតិវិធី អ.វ.ត.ក ត្រូវតែគោរពតាមលក្ខខណ្ឌតម្រូវ ប្រសិទ្ធិភាព នីត្យានុកូលភាព ភាពត្រឹមត្រូវយុត្តិធម៌ តាមក្របខណ្ឌគតិយុត្តិ អ.វ.ត.ក" ដើម្បីសម្រេចបាននូវ "យុត្តិធម៌ព្រហ្មទណ្ឌប្រកបដោយប្រសិទ្ធិភាព"[25]។

28. យ៉ាងណាមិញនៅចុងបញ្ចប់ អនុភាពចុងក្រោយនៅពេលដែល អ.ជ.ស.ដ មិនបានទទួលសិទ្ធិចូលពិនិត្យមើលដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងសំណុំរឿង មានន័យថា រឿងក្តីនេះនឹងត្រូវបានច្រានចោលដោយសន្ទត"[26]។ ការខកខានមិនបានផ្តល់លទ្ធភាពនេះនឹងរារាំងដល់ អ.ជ.ស.ដ ក្នុង

[23] ឯកសារ **D359/24** & **D360/33** សេចក្តីពិចារណា កថាខណ្ឌ ១១២។

[24] ឯកសារ **D359/24** & **D360/33** សេចក្តីពិចារណា កថាខណ្ឌ ១១២។

[25] ឯកសារ **D359/24** & **D360/33** សេចក្តីពិចារណា កថាខណ្ឌ ១០៩។

[26] ឯកសារ **A117/2/2** អ.ប.ជ សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបដិសេធតាមការសន្ទតលើសំណើលើកទីបួនរបស់ តា អាន សុំបំពេញកិច្ចស៊ើបសួរ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៤ កថាខណ្ឌ ១១: "ទ្រឹស្តីនៃការបដិសេធតាមការសន្ទត [...] អង្គជម្រះបុរេជំនុំជម្រះបានអនុវត្តសម្រាប់កាលៈទេសៈពិសេសទាំងឡាយ ដែលការិយាល័យសហចៅក្រមស៊ើបអង្កេតមិនមានសកម្មភាព ឬការពន្យារពេលវេលាក្នុងការបំពេញកិច្ច អាចបណ្តាលឱ្យមានព្យសនកម្ម"។

ការអនុវត្ត "ភារកិច្ចតាមផ្លូវតុលាការរបស់ខ្លួន ក្នុងការប្រកាសដោយផ្អែកទៅលើច្បាប់ នូវសេចក្តីសម្រេចលើបញ្ហាដែលមានវិវាទ [...] [ភារកិច្ចដែល] ជាចំណុចសំខាន់បំផុតនៃការទទួលខុសត្រូវ និងមុខងារដ៏ខ្ពង់ខ្ពស់របស់ចៅក្រម"[27]។ ក្នុងករណីនេះ បញ្ហាដែលមានវិវាទ គឺជាយុត្តាធិការរបស់ អ.ជ.ស.ដ ទៅលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ តាមសាច់រឿង ការខកខានដែលនៅតែបន្តក្នុងការផ្តល់នូវលទ្ធភាពដល់ អ.ជ.ស.ដ ក្នុងការចូលពិនិត្យដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងសំណុំរឿង គឺជាការបដិសេធនូវសិទ្ធិរបស់ជនជនចោទក្នុងការទទួលបានការជំនុំជម្រះក្តីដោយឆាប់រហ័ស សិទ្ធិរបស់ជនរងគ្រោះ និងភាគីដើមបណ្តឹងរដ្ឋប្បវេណីក្នុងការទទួលបានយុត្តិធម៌ ដែលធ្វើឲ្យខូចដល់សុចរិតភាពនៃដំណើរការរបស់ អ.វ.ត.ក និងបង្អាក់ដល់កិច្ចការគ្រប់គ្រងរដ្ឋបាលតុលាការដ៏ត្រឹមត្រូវក្នុងរឿងក្តីនេះ។

## V. ឧបាស្រ័យដែលស្នើឡើង

29. អាស្រ័យដូចមូលហេតុជម្រាបជូនខាងលើ សហព្រះរាជអាជ្ញាអន្តរជាតិ សូមស្នើឲ្យអង្គបុរេជំនុំជម្រះ ចាត់វិធានការរដ្ឋបាលដែលចាំបាច់ទាំងអស់ដើម្បីធានាថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងសំណុំរឿងដែលនៅសេសសល់នៃសំណុំរឿង ០០៤/២ (អោ អាន) ត្រូវបានបញ្ជូនជាបន្ទាន់ទៅអង្គជំនុំជម្រះសាលាដំបូង៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២០ | លោកស្រី Brenda J. HOLLIS<br>សហព្រះរាជអាជ្ញាអន្តរជាតិ | ភ្នំពេញ | |

[27] ឯកសារ **D359/24** & **D360/33** សេចក្តីពិចារណា, កថាខណ្ឌ ១២២។